ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៨០ អ.ក
ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩
សាលក្រមលេខ: ២៩ "ឲ"
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

## គានាមប្រជាពលរដ្ឋខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ០៩:០០ ព្រឹក លើបណ្តឹងទាស់ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ជាមេធាវីការពារក្តីឱ្យឈ្មោះ [redacted] គឹមអិន

លោកស្រី [redacted] ជាមេធាវីការពារក្តីឱ្យឈ្មោះ [redacted] លាង

លោក [redacted] ជាមេធាវីការពារក្តីឱ្យឈ្មោះ [redacted] គាង

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨០ អក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] គឹមអិន ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ហ៊ីម (ស្លាប់) ម្តាយឈ្មោះ [redacted] គឹមស្រ៊ាន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] សុផល មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្រៅឃុំ) ។

២-ឈ្មោះ [redacted] លាង ភេទប្រុស អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឆាយ (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្រពន្ធឈ្មោះ [redacted] រី មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្រៅឃុំ) ។

៣-ឈ្មោះ [redacted] គាង ភេទប្រុស អាយុ ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] គ្រុយ ម្តាយឈ្មោះ [redacted] ប្រាំង ប្រពន្ធឈ្មោះ [redacted] លាងកិច្ច មានកូន ០៤នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

-ត្រូវជាប់ចោទពីបទ៖ បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់ ប្រព្រឹត្តនៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។



Scanned with CamScanner

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៣៨៥ ដកសស ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៧៦១ ដកសព ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៨២៩ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

## ដំណាលរឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង៣០ នាទី មានករណីបើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់ និងលេងល្បែងស៊ីសងដោយខុសច្បាប់ (ជល់មាន់ និងអាប៉ោង) ប្រព្រឹត្តនៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ចាន់ឡេង ឈ្មោះ [redacted] គីមអិន ឈ្មោះ [redacted] ឈាង ឈ្មោះ [redacted] ហុង ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] គាង បានឃុបឃិតគ្នាបើកសង្វៀនជល់មាន់នៅទីតាំងខាងលើ ដោយមានអ្នកចូលរួមលេងម្តងចាប់ពី ៥០០ ទៅ ១០០០នាក់ ហើយជនសង្ស័យឈ្មោះ [redacted] គីមអ៊ិន និងឈ្មោះ ឈាង ជាអ្នកថ្លឹងទម្ងន់ និងផ្គូរផ្គងមាន់ ហើយយកគុងតម្លៃក្រោម១លានរៀល យកគុង៨ម៉ឺនរៀល រីឯជនសង្ស័យឈ្មោះ ចក់ ចាន់ឡេង ជាអាជ្ញាកណ្តាលក្នុង១គូដល់ប្រាក់ ៩០ម៉ឺនរៀល មិនតែប៉ុណ្ណោះនៅទីតាំងខាងលើក៏មាន បើកកន្លែងលេងអាប៉ោងភ្នាល់ដាក់លុយផងដែរ។ ក្រោយមកត្រូវបានសមត្ថកិច្ចចុះបង្ក្រាប និងឈានដល់ការចេញបញ្ជាឱ្យចូលខ្លួនចំពោះមេក្លោងខាងលើដោយឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ចាន់ឡេង ម្នាក់បញ្ជូនមកស្នងការនគរបាលខេត្តកណ្តាល ចំណែកជនសង្ស័យផ្សេងទៀតកំពុងរត់គេចខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

១. សំអាងហេតុដូចមាននៅក្នុងសាលក្រមលេខៈ ៤៥ ជជ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ គប្បីតុលាការទទួលស្គាល់សំអាងហេតុនៅក្នុងសាលក្រមនេះ។

២. នៅក្នុងកិច្ចពិភាក្សាដេញដោលជនជាប់ចោទបានឆ្លើយថាៈ

២.១ ជនជាប់ចោទឈ្មោះ [redacted] គីមអិន បានឆ្លើយថា នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩ ខ្លួនបានរៀបចំសង្វៀនជល់មាន់ស្ថិតនៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដោយខ្លួនបានឱ្យឈ្មោះ [redacted] ឈាង ឈ្មោះ [redacted] លាង និងឈ្មោះ គៀង បើកនិងធ្វើជាមេអាប៉ោងនៅទីនោះផងដែរ។ ខ្លួនបានពឹងឈ្មោះ [redacted] ចាន់ឡេង ឱ្យធ្វើជាអាជ្ញាកណ្តាលជំនួសខ្លួន ដោយនៅថ្ងៃនោះខ្លួនរវល់ទៅក្រៅ លុះក្រោយមកខ្លួនបានទទួលដំណឹងថាត្រូវបានសមត្ថកិច្ចចុះទៅបង្ក្រាបនៅទីតាំងរបស់ខ្លួន។ ភ្នាល់មាន់ជល់ក្នុងមួយគូរៗខ្លួនយកគុងក្នុងតម្លៃ៤ម៉ឺនរៀល ទៅ ៨ម៉ឺនរៀល ចំពោះអ្នកបើកអាប៉ោងនៅទីនោះបានមកសុំទីតាំងរបស់ខ្លួនដើម្បីបើក ហើយនិងចែកប្រាក់ចំណេញគ្នា ប៉ុន្តែនៅថ្ងៃនោះខ្លួនពុំទាន់បានទទួលប្រាក់ពីពួកគាត់ទេ ដោយសារតែទើបតែបើកបានមួយព្រឹកក៏ត្រូវសមត្ថកិច្ចចុះទៅបង្ក្រាបតែម្តង។



Scanned with CamScanner

២.២ ជនជាប់ចោទឈ្មោះ [redacted] លាង បានឆ្លើយថាខ្លួនបានអយ្យការចោទពីបទលេងល្បែងស៊ីសង ខ្លួនបើកពីរបីនាក់ [redacted] ឈាង ដាក់ហ៊ុនគ្នាម្នាក់ៗម្ភៃសាមសិបម៉ឺន ខ្លួនលេងអាប៉ោងតូចតាចទេ ខ្លួនសុំគេអែបជាមួយគេទេចំពោះល្បែងជល់មាន់។ ខ្លួនទើបលេងនៅរដូវចូលឆ្នាំទេ ថ្ងៃដំបូងខ្លួនចាញ់ដប់ម៉ឺនរៀល ខ្លួនមិនចាំមុខថាអ្នកណាលេងខ្លះទេ ពេលនេះគ្រួសារខ្លួនមិនមកទេ ព្រោះភ័យតក់ស្លុត។ ខ្លួនដឹងថាគេសុំច្បាប់ដែល ទើបខ្លួនទៅលេង ពេលសមត្ថកិច្ចចុះចាប់ខ្លួនមិននៅទីនោះទេ។ ឥឡូវខ្លួនដឹងខ្លួនខុសហើយ ខ្លួនឈប់លេងហើយ ។

២.៣ ជនជាប់ចោទឈ្មោះ [redacted] គាង បានឆ្លើយថាខ្លួនលេងអាប៉ោងពិតប្រាកដមែន ហើយខ្លួនជាអ្នកស៊ីសងឱ្យឈ្មោះ [redacted] ឈាង។ ពេលលេងបានចូលហ៊ុនគ្នាម្នាក់ម្ភៃទៅសាមសិបម៉ឺនរៀល នៅពេលឈ្មោះបង់អោយឈ្មោះ [redacted] គឹមអិន។ ខ្លួនស្គាល់ឈ្មោះពួកគេច្បាស់ ខ្លួនទទួលតែផ្នែកអាប៉ោងទេ ពេលឈ្មោះខ្លួនឱ្យទៅគេបើចាញ់អត់បានលុយទេ ហើយខ្លួនដឹងថាការមើលការខុសត្រូវមានទោស ។

យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងបីខាងលើ គឺអាចឱ្យតុលាការពិចារណាអំពីការសម្រេចនៅក្នុងសាលក្រមលេខ ៤៥ ជជ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល។

៣. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា រឿងនេះជំនុំជម្រះពីរដងហើយ ខ្ញុំសូមសរសើរអ្នកបានប្រព្រឹត្ត ហើយហ៊ានសារភាព ខ្ញុំសូមតម្កល់នូវការចោទប្រកាន់តាមមាត្រា៩៨ដែល គប្បីតុលាការធ្វើការព្យួរទោសដល់ជនជាប់ចោទទៅ ប៉ុន្តែត្រូវឱ្យជនជាប់ចោទបង់ប្រាក់ពិន័យផង។

៤. មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖

៤.១ លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គឹមអិន បានធ្វើសេចក្តីសន្និដ្ឋានថាកូនក្តីខ្លួនទើបតែប្រព្រឹត្តលើកដំបូង ហើយប្រព្រឹត្តនូវថ្ងៃចូលឆ្នាំទៀត លើសពីនេះកូនក្តីខ្លួនសន្យាថាលែងហ៊ានប្រព្រឹត្តទៀតហើយ និងធ្វើជាពលរដ្ឋល្អ ហេតុនេះសូមឱ្យតុលាការព្យួរទោស និងពិន័យជាប្រាក់ក្នុងចំនួនតិចតួចបានហើយ។

៤.២ លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លាង បានធ្វើសេចក្តីសន្និដ្ឋានថាសូមឱ្យតុលាការបន្ធូបន្ថយទោសដល់កូនក្តីខ្លួនផង ព្រោះគាត់មានវ័យចាស់ ហើយទើបតែលេងបានម្តង និងបានទទួលស្គាល់នូវកំហុស ចំពោះការពិន័យជាប្រាក់សុំឱ្យតុលាការពិន័យតិចតួចបានហើយ។

៤.៣ លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គាង បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានទទួលស្គាល់កំហុសហើយ ប៉ុន្តែកំហុសនេះជាលើកទី១ ពីមុនមកកូនក្តីខ្លួនមិនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹងល្បែងស៊ីសងនោះទេ ហើយកូនក្តីខ្លួនជាកសិករមានជីវភាពខ្វះខាត់ខ្សោយ ជាក់ស្តែងកូនក្តីខ្លួនជាមេគ្រួសារត្រូវធ្វើការងាររកស៊ី ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ លើសពីនេះកូនក្តីខ្លួនជាមនុស្សរៀនសូត្របានតិចតួច ខ្វះការយល់ដឹង ជាហេតុមិនបានដឹងថាការប្រព្រឹត្តរបស់ខ្លួនជាអំពើខុសច្បាប់ ម្យ៉ាងទៀតដោយគិតថាពេលនោះជាថ្ងៃចូលឆ្នាំផង។

៥. ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវី យល់ឃើញថា ជនជាប់ចោទមានវ័យចំណាស់ មានជីវភាពក្រីក្រ មានការទទួលស្គាល់ និងសន្យាកែប្រែកំហុសរបស់ខ្លួន ហើយបានស្នើសុំឱ្យតុលាការធ្វើការព្យួរទោស ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោស ដោយកែប្រែសេចក្តីសម្រេចនៃសាលក្រមលេខ ៤៥ ជជ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុច ២.ក និងចំណុច ៣ នៃការផ្តន្ទាទោសឈ្មោះ [redacted] គឹមអិន, [redacted] លាង និងឈ្មោះ [redacted] គាង មកជា៖

៥.១ ផ្តន្ទាទោសឈ្មោះ [redacted] គឹមអិន ០១ឆ្នាំ អនុវត្តទោសព្យួរ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល គប្បីតុលាការពិចារណា។

៥.២ ផ្តន្ទាទោសឈ្មោះ [redacted] លាង ០១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល ដោយអនុវត្តទោសទាំងពីរនេះព្យួរ គប្បីតុលាការពិចារណា។



Scanned with CamScanner

៥.៣ ផ្តន្ទាទោសឈ្មោះ [redacted] គាង ០១ឆ្នាំ អនុវត្តទោស ០២ ខែ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល ដោយអនុវត្តទោសទាំងពីរនេះព្យួរ គប្បីតុលាការពិចារណា ។

៦. ជនជាប់ចោទឈ្មោះ [redacted] គីមអ៊ិន, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] គាង សុំឱ្យតុលាការព្យួរទោស និងលើកលែងទោសដល់ពួកខ្លួនផង ខ្លួនទទួលស្គាល់នូវកំហុសហើយ ។

**ហេតុដូច្នេះសម្រេច**

១. ផ្តន្ទាទោសជនជាប់ចោទ៖

ក. ឈ្មោះ [redacted] គីមអ៊ិន ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ ដោយអនុវត្តទោសព្យួរ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល ។

ខ. ឈ្មោះ [redacted] លាង ភេទប្រុស អាយុ ៦៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល ដោយអនុវត្តទោសទាំងពីរនេះព្យួរ។

គ. ឈ្មោះ [redacted] គាង ភេទប្រុស អាយុ ៥៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ អនុវត្តទោសចំនួន ០២ ខែ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០៛ (ប្រាំលាន) រៀល ដោយអនុវត្តទោសទាំងពីរនេះព្យួរ។

ពីបទៈ បើកកន្លែងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។

២. ចេញដីកាបញ្ឈប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] គីមអ៊ិន និងឈ្មោះ [redacted] លាង ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គីមអ៊ិន, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] គាង។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កណ្តាល,ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០,

បានឃើញ
ចៅក្រមជំនុំជម្រះ

ក្រឡាបញ្ជី

[redacted]

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល, ថ្ងៃទី 03 ខែ ... ឆ្នាំ 2020
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner